00651456

F2/3

# នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| ឯកសារទទួល |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 03 / 2011 |
| ម៉ោង (Time/Heure): 15:00 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun |

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

កាលបរិច្ឆេទឯកសារ: ១១ មិនា ឆ្នាំ២០១១

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សុំដាក់ភស្តុតាងបន្ថែម ដើម្បីគាំទ្របណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក Karim A. A. Khan

លោកស្រី ទី ស្រ៊ីនណា

លោក Alain WERNER

លោកស្រី Brianne McGONIGLE

<u>ដោយមានជំនួយពី</u>៖

លោកស្រី Daniella RUDY

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម

ចៅក្រម Motoo Noguchi

ចៅក្រម សោម សេរីវុឌ្ឍន៍

ចៅក្រម Agniezska KLONOWIECKAMILART

ចៅក្រម ស៊ិន រិទ្ធិ

ចៅក្រម Chandra Nihal Jayasinghe

លោក Kate GIBSON

**ចម្លងជូន៖**

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ៖**

លោក ការ សាវុត្ថ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោកPhillipe CANONNE

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

លោក Pierre-Oliver SUR

00651458

F2/3

## I. សេចក្តីផ្តើម

១. មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ស្នើសុំដោយក្តីគោរព ដោយយោងតាមវិធាន១០៨ (៧) (វិសោធនកម្មលើកទី៦) នៃវិធានផ្ទៃក្នុង មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ត្រូវបានអនុញ្ញាតឱ្យដាក់ជូននូវភស្តុតាងបន្ថែមដើម្បីគាំទ្របណ្តឹងសារទុក្ខរបស់ពួកគេប្រឆាំងទៅនឹង សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។[1]

## II. ប្រវត្តិ

២. នៅក្នុងសាលក្រមកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃសារជាថ្មីទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់មកបានដកហូតឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចេញពីអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩នាក់ ដែលមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ជាមេធាវីការពារក្តី។[2]

៣. ដោយយោងតាមវិធាន១០៤ (៤) (វិសោធនកម្មលើកទីបី) នៃវិធានផ្ទៃក្នុង នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានដាក់ជូននូវបណ្តឹងសារទុក្ខជាបន្ទាន់ប្រឆាំងនឹងការសម្រេចលើឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ (បណ្តឹងសារទុក្ខជាបន្ទាន់) តំណាងឱ្យអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩នាក់ ដែលរួមមាន លី ហ៊ (E2/61); Joshua ROTHSCHILD (E2/88); Jeffrey JAMES (E2/86); (E2/62); សួន សៀង (D25/15); ង៉ែត អ៊ុយ (E2/74); ផៀវ នាប (E2/75); និង លឹម យ៉ុន (E2/69) និង នង សាវ៉ាត់ (E2/73) ។[3]

៤. កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល បានធ្វើការណែនាំមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ឱ្យដាក់ជូនឡើងវិញនូវបណ្តឹងសារទុក្ខ ដោយមានបញ្ចូលនូវលិខិតប្រគល់សិទ្ធិដោយអណត្តិ។ បន្ទាប់មក មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានដាក់ឡើងវិញនូវបណ្តឹងសារទុក្ខជាបន្ទាន់ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ដោយមានភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិតំណាងដោយអណត្តិ។

---

[1] F18.

[2] E188, ទំព័រ 225-229.

[3] E188/10.

F213

៥. កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើលក្ខណៈនៃបណ្តឹងសារទុក្ខជាបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដោយរកឃើញថា បណ្តឹងសារទុក្ខនេះស្ថិតនៅក្នុងរបបនីតិវិធីដែលពាក់ព័ន្ធនឹងការប្តឹងសារទុក្ខប្រឆាំងនឹងសាលក្រម។[4] បន្ទាប់មកដើម្បីជាប្រយោជន៍ដល់យុត្តិធម៌ អង្គជំនុំជម្រះតុលាការកំពូល បានចាត់ទុកបណ្តឹងសារទុក្ខជាបន្ទាន់នេះថាជាសេចក្តីជូនដំណឹងអំពីការប្តឹងសារទុក្ខ និងជាសារណាបណ្តឹងសារទុក្ខ។

៦. ក្នុងការត្រៀមខ្លួនសម្រាប់សវនាការបណ្តឹងសារទុក្ខដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី២៨ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ បានជូនដំណឹងដល់មេធាវីតំណាងដើមបណ្តឹងប្បវេណីក្រុម១ ឲ្យព្យាយាមដាក់ជូននូវភស្តុតាងបន្ថែមឲ្យបានមុនថ្ងៃសុក្រ ទី១១ ខែមិនា ឆ្នាំ២០១១។

## III. សេចក្តីស្នើសុំ

៧. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដោយក្តីគោរព ស្នើសុំដាក់ជូននូវសក្ខីកម្មសាក្សីបន្ថែមចំនួន ២ ក្នុងការបង្ហាញនូវទំនាក់ទំនងគ្រួសាររវាង E2/62 និងបងប្រុសរបស់គាត់ដែលជាជនរងគ្រោះផ្ទាល់នៅមន្ទីរស-២១។ សក្ខីកម្មទាំងពីរនេះគឺបានមកពីបងស្រីរបស់ E2/62 និងពីមេភូមិដែលជាមិត្តភក្តិរបស់ជនរងគ្រោះដោយផ្ទាល់។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមដាក់ជូនបន្ថែមផងដែរនូវស្នាមមេដៃរបស់ លី ហ៊ី (E2/61) ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូល អាចធ្វើការប្រៀបធៀបស្នាមមេដៃនេះទៅនឹងស្នាមមេដៃដែលមានផ្តិតនៅលើចម្លើយរបស់គាត់នៅមន្ទីរស-២១។[5]

៨. វិធាន ១០៨ (៧) (វិសោធនកម្មទី៦) បានចែងដោយផ្នែកថា "ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល បើសិនជាភស្តុតាងនោះមិនអាចរកបាននៅក្នុងសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តី ស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់រវាងភស្តុតាងបន្ថែមថ្មីនោះ ជាមួយនឹងសម្អាងហេតុជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក"។

---

[4] F811.

[5] "ចម្លើយសារភាពរបស់ អ៊ា ហ៊ី" E2/61.2/ERN 00361722.

៩. ដើមបណ្តឹងរដ្ឋប្បវេណី E2/62 លើកឡើងថា បងប្រុសរបស់គាត់ត្រូវបានឃុំឃាំង និង សម្លាប់នៅមន្ទីរស-២១។ គាត់អាចផ្តល់ជូននូវរូបថតពីបណ្ណសារដ្ឋានរបស់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។[6] ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា រូបថតនេះមិនមានផ្តល់អត្តសញ្ញាណ និង មិនបានបញ្ជាក់ថា អ្នកនៅក្នុងរូបថតជានរណានោះទេ។[7] អង្គជំនុំជម្រះសាលាដំបូងបានរកឃើញទៀតថា មិនមានឯកសារណាមួយដែលអាចធ្វើការបង្ហាញពីភាពពិតនៃទំនាក់ទំនងរបស់គាត់ជាមួយនឹងជនរងគ្រោះ ដោយផ្ទាល់[8] នោះទេ ហើយជាលទ្ធផល បានដកហូតនូវឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ E2/62។

១០. ដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា (E2/61) បានអះអាងថា គាត់ត្រូវបានឃុំឃាំងជាដំបូងនៅមន្ទីរស-២១ និងក្រោយមក នៅមន្ទីរស-២៤ ហើយនៅមន្ទីរស-២៤នោះឯងដែលគាត់បានលួចរត់។[9] អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ថាឈ្មោះ អ៊ា ហ៊ា ពិតជាត្រូវឃុំឃាំងនៅមន្ទីរស-២១មែន បើយោងទៅតាមឯកសារដែលបានដាក់ជូនតុលាការ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមានការសង្ស័យមិនច្បាស់លាស់ថា ដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា (E2/61) ពិតជាបុគ្គលឈ្មោះ អ៊ា ហ៊ា។ ដោយសារមូលហេតុនេះ អង្គជំនុំជម្រះបានរកឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់មិនគ្រប់តាមលក្ខណ្ឌតម្រូវ។

១១. ភស្តុតាងបន្ថែមដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ស្វះស្វែងដាក់ជូនអង្គជំនុំជម្រះតុលាការកំពូល មិនអាចរកបាននៅក្នុងដំណាក់កាលជំនុំជម្រះទេ ដោយហេតុថា អង្គជំនុំជម្រសាលាដំបូងមិនបានជូនដំណឹងឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ទៅដល់ភាគីទាំងឡាយនូវលក្ខណ្ឌចាំបាច់ដែលអង្គជម្រះជំនុំសាលាដំបូងនឹងយកមកពិចារណានៅពេលធ្វើសេចក្តីសម្រេចអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។[10] អង្គជំនុំជម្រះសាលាដំបូងក៏ខកខានផងដែរ ក្នុងការជូនដំណឹងដល់ភាគីអំពីបទដ្ឋាននៃការពិនិត្យឡើងវិញ និង ភស្តុតាងដែលអង្គជំនុំជម្រះតម្រូវឱ្យមាន សម្រាប់ការពិចារណាឡើងវិញនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះដែរ។[11]

---

[6] សូមមើល "រូបថតថតនៅមន្ទីរស-២១" E165/1/1.2; "សំបុត្របញ្ជាក់ដោយប្រធានសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង" E165/1/1.3.

[7] E188, វាក្យខណ្ឌ 648.

[8] E188, វាក្យខណ្ឌ 648.

[9] ប្រតិចារិក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៩។

[10] E188/10.

[11] E188/10.

00651461

F2/3

១២. ដើម្បីជួយគាំទ្រចំពោះអំណះអំណាងដែលបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនាក់ខាងលើនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ធ្វើការស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូលដោយក្តីគោរព ឲ្យទទួលយកនូវភស្តុតាងបន្ថែមទាំងនេះ ដើម្បីគាំទ្រដល់បណ្តឹងសារទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលចេញ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

ដាក់ជូនដោយក្តីគោរព:

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម១)

Karim A. A. Khan　　ទី ស្រ៊ីនណា　　Alain Werner

Brianne McGonigle　　Daniella Rudy　　Kate Gibson